01200436

លេខ៖ D286/7

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / 02 / 2016
ម៉ោង (Time/Heure): 09:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦**

ភាសា ៖ **អង់គ្លេស/ខ្មែរ [អង់គ្លេស ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ [សាធារណៈ]

# ដីកាសម្រេចបំបែកសំណុំរឿងនាក់ឯង អ៊ឹម ចែម ចេញពីសំណុំរឿង 004

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្ដីអោ អាន**
មុំ លុច
Richard ROGERS
Göran SLUITER

**មេធាវីការពារក្ដីអ៊ឹម ចែម**
ប៊ិត ស៊ាងលឹម
John R.W.D. Jones

**មេធាវីការពារក្ដីយឹម ទិត្យ**
សូ មូស្សេនី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

01200437

០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស លេខ៖ D286/7

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានជូនដំណឹងជាសាធារណៈទៅភាគី និងមេធាវីរបស់ភាគីទាំងអស់អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម ហើយបានផ្តល់ពេលវេលាជូនពួកគាត់រហូតដល់ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ ដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែម("សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ")[1]។ នៅថ្ងៃដដែលនេះ

[កោសលុប]

ស.ច.ស បានស្នើ ភាគីទាំងអស់ សុំដាក់នៅត្រឹមថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦ នូវសារណាដែលខ្លួនអាចមានអំពីការបំបែកចេញនូវសំណុំរឿង អ៊ឹម ចែម ("សេចក្តីជូនដំណឹងអំពីគោលបំណង [កោសលុប] ")[2]។

២. នៅថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញា ដោយកត់សម្គាល់ថា មានភាពមិនច្បាស់លាស់រវាងសំណៅជាភាសាអង់គ្លេស និងជាភាសាខ្មែរនៃសេចក្តីជូនដំណឹងអំពីគោលបំណង [កោសលុប] ក៏បានដាក់សំណើសុំការបញ្ជាក់ទាក់ទងនឹងសំណើដែល ស.ច.ស បានស្នើឡើង[3]។ នៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ ស.ច.ស បានផ្តល់ការបញ្ជាក់តាមសំណើនេះ ហើយបានពន្យារពេលកំណត់ដាក់សារណាដែលបានកំណត់នៅក្នុងសេចក្តីជូនដំណឹងអំពីគោលបំណង [កោសលុប] រហូតដល់ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦[4]។

---

[1] សំណុំរឿង ០០៤ ឯកសារ D285 *សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម* ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៥។

[2] [កោសលុប]

[3] សំណុំរឿង ០០៤ ឯកសារ D286/1 *សំណើរបស់សហព្រះរាជអាជ្ញា សុំការបញ្ជាក់លើសារណាដែលបានស្នើដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងសេចក្តីជូនដំណឹងអំពីគោលបំណងរបស់ខ្លួនចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥,* ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៥។

[4] សំណុំរឿង ០០៤ ឯកសារ D286/1/1 *ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំការបញ្ជាក់លើសារណាដែលសហចៅក្រមស៊ើបអង្កេត បានស្នើនៅក្នុងសេចក្តីជូនដំណឹងអំពីគោលបំណងរបស់ខ្លួនចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥,* ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦។

៣. នៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ មេធាវីការពារក្ដី បានដាក់សារណាគាំទ្រការបំបែកសំណុំរឿង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤[5]។ នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញា បានជូនដំណឹង ស.ច.ស ថា ខ្លួនមិនជំទាស់នឹងការបំបែកសំណុំរឿងនេះទេ[6]។

## II. ពិភាក្សា

៤. មាត្រា ១៤ (៣)(គ) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ ១៩៦៦ ចែងថា ក្នុងការសម្រេចសេចក្ដីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការជំនុំជម្រះដោយឥតពន្យារពេល ។ វិធានផ្ទៃក្នុង ២១(៤) តម្រូវថា ការសម្រេចសេចក្ដីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប។ ដោយយល់ឃើញថា កិច្ចស៊ើបសួរលើការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម បានបញ្ចប់ហើយខណៈដែលកិច្ចស៊ើបសួរប្រឆាំងជនត្រូវចោទផ្សេងទៀតនៅក្នុងសំណុំរឿង ០០៤ នៅបន្តដំណើរការនោះ ទើប យើង យល់ឃើញថា ជាការត្រឹមត្រូវ និងដើម្បីជាប្រយោជន៍ភាគីទាំងអស់ គឺត្រូវបំបែកសំណុំរឿង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤។

៥.
[កោសលុប]

៦.
[កោសលុប]

---

5

i [កោសលុប]

{

[6] សំណុំរឿង ០០៤ ឯកសារ D286/3 *សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្ដីពីការបំបែកសំណុំរឿងប្រឆាំង អ៊ឹម ចែម* ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៦។ *សូមមើលផងដែរ* សំណុំរឿង ០០៤ ឯកសារ D286/3/2 *ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបរបស់មេធាវីការពារក្ដី ស្ដីពីការបំបែកសំណុំរឿងប្រឆាំងនឹង អ៊ឹម ចែម* ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៦។

7 [កោសលុប]

[កោសលុប]

**តាមសំអាងហេតុខាងលើ យើង**[8]៖

៧. **បង្គាប់ឲ្យ** បំបែកសំណុំរឿងប្រឆាំង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤។

៨. **បង្គាប់** ក្រឡាបញ្ជី ត្រូវធ្វើការចាត់ចែងដែលចាំបាច់ដើម្បីបង្កើតសំណុំរឿងថ្មី ដាក់លេខ ០០៤/០១ ដែលអាចចូលពិនិត្យមើលបានពីសំណាក់ភាគីទាំងអស់ ដែលបច្ចុប្បន្ននេះមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ០០៤។

៩.

[កោសលុប]

១០. **ជូនដំណឹង** មេធាវីការពារក្តី យឹម ទិត្យ និងមេធាវីការពារក្តី អេ អាន ថា ពួកគាត់ទទួលបានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ០០៤/០១ ពីព្រោះថា ការដាក់ឯកសារ និងសេចក្តីសម្រេចដែលចេញនៅក្នុងសំណុំរឿងនេះនាពេលអនាគតអាចពាក់ព័ន្ធនឹងការតំណាងឲ្យកូនក្តីរបស់ខ្លួននៅក្នុងសំណុំរឿង ០០៤។ ប៉ុន្តែ សិទ្ធិចូលពិនិត្យមើលសំណុំរឿង ០០៤/០១ មិនមែនមានន័យជាស្វ័យប្រវត្តិថា មានសិទ្ធិដាក់សារណា ឬសំណើនៅក្នុងសំណុំរឿងនេះទេ។

---

[8] សហចៅក្រមស៊ើបអង្កេតទាំងពីរ ចេញដីកានេះរួមគ្នា ប៉ុន្តែ ដើម្បីទុកជាកំណត់ហេតុ សហចៅក្រមស៊ើបអង្កេតជាតិ កត់សម្គាល់ថា ឯកសារនានាដាក់ចូលក្នុងសំណុំរឿង ០០៤ គួរដាក់លេខរៀងបន្តពីឯកសារចុងក្រោយដែលបានដាក់ចូលក្នុងសំណុំរឿងមុនពេលការលាលែងតំណែងរបស់ចៅក្រម Siegfried Blunk ដោយមិនបញ្ចូលឯកសារដីកា និងដីកាសម្រេចដែលចេញដោយចៅក្រមបម្រុង Laurent Kasper-Ansermet ទេ។

០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស លេខ៖ D286/7

ភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦

**សហចៅក្រមស៊ើបអង្កេត**

Co-Investigating Judges

Co-juge d'instruction

**យូ ប៊ុនឡេង** **Michael BOHLANDER**